២–បទបញ្ជាផ្ទៃក្នុងត្រូវអនុវត្តបទបញ្ញត្តិទូទៅនៃច្បាប់ការងារ តាមប្រភេទសហគ្រាស និងវិធានទូទៅនៃការងារ ដែលស្តីពីផ្នែកសកម្មភាពនៃសហគ្រាសជាអាទិ៍គឺ បទបញ្ញត្តិទាក់ទងនឹងលក្ខខ័ណ្ឌ ទទួលធ្វើការគិត និងការបើកប្រាក់ឈ្នួល និងកំរៃបន្ទាប់បន្សំទាក់ទងនិងតាវកាលិកធម្មជាតិ ពេលម៉ោងធ្វើការ ពេលសំរាក និងការឈប់សំរាក ការអោយដំណឹងមុន វិធានការអនាម័យ និងសន្តិសុខ និយោជិត កម្មករ កាតព្វកិច្ចនិយោជិត កម្មករ និងទណ្ឌកម្ម ដែលនឹងតម្រូវលើនិយោជិត កម្មករ ដូចមានគំរូជាឧបសម្ព័ន្ធនៃសេចក្តីជូនដំណឹងនេះ ។

៣–បទបញ្ជាផ្ទៃក្នុង ត្រូវរៀបចំឡើងដោយម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានក្រោយពីបានពិគ្រោះ និងប្រតិភូបុគ្គលិក ក្នុងរយៈពេល ៣ខែបន្ទាប់ពីថ្ងៃបើកសហគ្រាសគ្រឹះស្ថាន ។

ក្រោយពេលកសាងរួចហើយ ម្ចាស់ឬនាយកសហគ្រាស គ្រឹះស្ថានត្រូវបញ្ជូនបទបញ្ជាផ្ទៃក្នុងនោះ ចំនួនពីរច្បាប់ ដោយមានភ្ជាប់ទាំងមតិយោបល់ជាលាយលក្ខណ៍អក្សររបស់ប្រតិភូបុគ្គលិកផងទៅសុំចុះទិដ្ឋាការ អំពីអធិការ ការងារ មុននឹងដាក់អោយប្រើប្រាស់ជាផ្លូវការ ។

សហគ្រាស គ្រឹះស្ថានទាំងអស់នៅភ្នំពេញ ត្រូវបញ្ជូនបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ទៅស្នើសុំចុះទិដ្ឋាការនៅនាយកដ្ឋានអធិការកិច្ច ការងារ នៃក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនដែល ស្ថិតនៅ ផ្ទះលេខ ២៨ វិថីសម្តេចព្រះធម្មលិខិតអ៊ុក «ផ្លូវលេខ ១៨៤» សង្កាត់ជ័យជំនះខ័ណ្ឌ ដូនពេញ រាជធានីភ្នំពេញ ។ ចំណែកសហគ្រាសគ្រឹះស្ថាននៅតាមខេត្ត-ក្រុង ត្រូវបញ្ជូនទៅអធិការដ្ឋាន សង្គមកិច្ច ការងារ និងអតីតយុទ្ធជនខេត្ត ក្រុងនៃមូលដ្ឋានខ្លួន ដើម្បីស្នើសុំចុះទិដ្ឋាការ ។

៤–បើបទបញ្ជាផ្ទៃក្នុងមានការខ្វះចន្លោះ អធិការការងារនឹងជូនដំណឹងអោយម្ចាស់សហគ្រាសគ្រឹះស្ថាន យកទៅកែសំរួលអោយសមស្របឡើងវិញ ។ ក្រោយពីបានទទួលដំណឹងនេះម្ចាស់ ឬនាយកសហគ្រាសគ្រឹះស្ថានត្រូវធ្វើ ការកែសំរួលឡើងវិញភ្លាម ។

ម្ចាស់ ឬនាយកសហគ្រាសគ្រឹះស្ថានមានសិទ្ធិប្តឹងតវ៉ាទៅរដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ពីការមិនសុខចិត្តរបស់ខ្លួន ចំពោះការជូនដំណឹងរបស់អធិការការងារ ។ ការប្តឹងតវ៉ានេះ មិនជំទាស់នឹងមតិយោបល់របស់អធិការការងារ ដែលបានជូនដំណឹងដល់ម្ចាស់ ឬ

នាយកសហគ្រាស គ្រឹះស្ថានឡើយ នៅពេលពុំទាន់មានសេចក្តីសំរេចជាផ្លូវការ ពីរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ។

៥_បទបញ្ជាផ្ទៃក្នុងដែលបានចុះទិដ្ឋាការ ពីអធិការការងារអោយប្រើប្រាស់ជាផ្លូវការហើយនោះ ត្រូវតែបិទផ្សាយ នៅទីណាមួយដ៏សមរម្យ អាចចូលទៅមើលបានដោយងាយក្នុងកន្លែងធ្វើការ ហើយនិងនៅមាត់ទ្វារបន្ទប់សំរាប់ទទួលយកអ្នកស៊ីឈ្នួលអោយធ្វើការ ។

បទបញ្ជាផ្ទៃក្នុងនេះ ត្រូវតែថែរក្សាទុកដាក់អោយបានល្អ អានបានច្បាស់ជាដរាប ។

៦_ការកែប្រែគ្រប់បែបយ៉ាងនៃបទបញ្ជាផ្ទៃក្នុង ត្រូវតែអនុវត្តតាមបែបបទ និងនីតិវិធីដូចគ្នា នឹងការរៀបចំកសាងបទបញ្ជាផ្ទៃក្នុងដែរ ។

៧_សេចក្តីជូនដំណឹងរបស់ក្រសួងសង្គមកិច្ច ការងារនិងអតីតយុទ្ធជន លេខ ១២សកអ. ចុះថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ ១៩៩៦ ត្រូវចាត់ទុកជានិរាករណ៍ ។

ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនសង្ឃឹមថា ម្ចាស់ ឬនាយកសហគ្រាសគ្រឹះស្ថាន រោងចក្រ ឧស្សាហកម្ម រ៉ែ ពាណិជ្ជកម្ម សិប្បកម្ម សេវា ទាំងអស់នឹងអនុវត្ត តាមសេចក្តីជូនដំណឹងនេះ អោយបានទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់ជាពុំខាន ។

រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ
និងអតីតយុទ្ធជន
ហត្ថលេខា និង ត្រា
ស៊ុយ សែម

*****

ឧសម្ព័ន្ធ
នៃសេចក្តីជូនដំណឹងលេខ ០៩ សកអ.
ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ១៩៩៧
(គំរោងបទបញ្ជាផ្ទៃក្នុង)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
****

បទបញ្ជាផ្ទៃក្នុង

របស់សហគ្រាស.................................

I_ បទបញ្ញត្តិស្តីពីវិន័យការងារ

ប្រការ ១ : _ល័ក្ខខ័ណ្ឌទទួលយកនិយោជិត កម្មករ អោយធ្វើការ
_បែបបទផ្សេងៗដែលនិយោជិត កម្មករត្រូវបំពេញមុនចូលបំរើការងារ
_អាស័យដ្ឋានរបស់និយោជិត កម្មករ ស្ថានភាពគ្រួសារការផ្លាស់ប្តូរផ្សេងៗនៅពេលក្រោយមកទៀត,
_ការហ៊ឹកហ្វឺនកូនជាង
_ការសាកល្បងការងារ ។

ប្រការ ២ : _បែបបទនៃការអនុវត្តន៍ការងារក្នុងសហគ្រាស
_របៀបរបប និងសណ្តាប់ធ្នាប់ល្អក្នុងសហគ្រាស

ប្រការ ៣ : _ការពិនិត្យកាយសម្បទានៅគ្រាដំបូង
_ការពិនិត្យសុខភាពជាកាលិក ។

ប្រការ ៤ : _ពេលម៉ោងធ្វើការ គិតទាំងការធ្វើការនៅពេលយប់ និងការប្តូរវេនធ្វើការ
_ការឈប់សំរាក ប្រចាំសប្តាហ៍
_ការឈប់សំរាកប្រចាំឆ្នាំ ឈប់សំរាកពេលបុណ្យ ឈប់សំរាកពិសេស
_ការសំរាកសំរាលកូនរបស់និយោជិតកម្មករជាស្ត្រី ។
_ការឈប់សំរាកដោយជម្ងឺ

ប្រការ ៥ : _ការកំណត់ប្រាក់ឈ្នួល ប្រាក់រង្វាន់ និងប្រាក់បន្ទាប់បន្សំផ្សេងៗ

-ការបើកប្រាក់ឈ្នួល
-ការកាត់ប្រាក់ឈ្នួល ។

ប្រការ ៦ : -អវត្តមានរបស់និយោជិត កម្មករ :
-អវត្តមានមានច្បាប់អនុញ្ញាតត្រឹមត្រូវ
-អវត្តមានដោយអត់ច្បាប់អនុញ្ញាត ។

ប្រការ ៧ : -ការប្រើប្រាស់សំភារៈ និងហត្ថូបករណ៍របស់សហគ្រាសក្នុងការបំពេញការងារ ។

ប្រការ ៨ : -ការប្រើប្រាស់អគារ ឬ មូលដ្ឋានរបស់សហគ្រាស ។

មាត្រា ៩ : -ការចេញ និង ចូលសហគ្រាស ។

II-ការដាក់ទោសវិន័យ និងសិទ្ធិការពារខ្លួនរបស់និយោជិត កម្មករ

ប្រការ ១០: -ការកំណត់ទោសផ្សេងៗដល់និយោជិត កម្មករដែលបានរំលោភលើបទបញ្ជាផ្ទៃក្នុង ឬដែលមានកំហុសធ្ងន់ ។

ប្រការ ១១: -សិទ្ធិការពារខ្លួនរបស់និយោជិត កម្មករ នៅមុនពេលត្រូវទទួលទោសវិន័យ ។

III-អនាម័យ និងសន្តិសុខការងារ

ប្រការ ១២: -វិធានការនានានៃអនាម័យការងារ និងសន្តិសុខការងារ
-កាតព្វកិច្ចរបស់និយោជិត កម្មករ ក្នុងការគោរព និងអនុវត្តន៍តាមវិធានការខាងលើ
-ការបង្ការគ្រោះថ្នាក់ការងារ និងជម្ងឺវិជ្ជាជីវៈ ។

...............ថ្ងៃទី..........ខែ..........ឆ្នាំ ១៩៩...
(ហត្ថលេខា របស់នាយកសហគ្រាស)

កន្លែងចុះទិដ្ឋាការរបស់
អធិការការងារ

* * * * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ១៩៩៧

ប្រកាសលេខ ៩២ សករអ.

ស្តីពី

សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន

****

រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ ស្តីពីការងារដែលប្រកាសអោយ ប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៧
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

សំរេច

ប្រការ ១ : នាយក ឬម្ចាស់សហគ្រាស គ្រឹះស្ថានឧស្សាហកម្មរ៉ែ ពាណិជ្ជកម្ម សិប្បកម្ម កសិកម្ម សេវា ដឹកជញ្ជូនតាមផ្លូវគោក ឬតាមផ្លូវទឹក ជាប្រយោជន៍សាធារណៈ ឬពាក់កណ្តាលសាធារណៈ ឬ ឯកជន ក្រៅសាសនា ឬក្នុងសាសនា ទោះមានលក្ខណៈជាការបង្រៀនវិជ្ជាជីវៈ ឬជាការកុសលក៏ដោយ ព្រមទាំងវិជ្ជាជីវៈសេរីនៃសមាគម ឬក្រុមប្រភេទណាក៏ដោយ ត្រូវប្រើ និងរក្សាទុកអោយបានត្រឹមត្រូវនូវសៀវភៅបញ្ជីប្រចាំគ្រឹះស្ថានមួយដែលអធិការការងារបានចុះលេខរៀង និងចុះហត្ថលេខាសង្ខេប ដូចមានសៀវភៅបញ្ជីគំរូជា ឧបសម្ព័ន្ធនៃប្រកាសនេះ ។

ប្រការ ២ : និយោជក ឬ អ្នកតំណាងត្រូវជូនសៀវភៅបញ្ជីនេះទៅអធិការការងារ ឬ អភិបាលការងារ ត្រួតពិនិត្យ និងធ្វើការសង្កេត ឬការដាក់កំហិតផ្សេងៗនៅរាល់ពេលចុះត្រួតពិនិត្យ ។

ប្រការ ៣ : សៀវភៅបញ្ជីណាដែលបានប្រើប្រាស់គ្រប់ទំព័រទាំងអស់ហើយ និយោជកត្រូវថែរក្សាទុកអោយគង់ក្នុងរយៈពេល៣ឆ្នាំ ។ អធិការការងារ និងអភិបាលការងារអាចទាររកសៀវភៅនោះនៅគ្រប់ពេលវេលា ។

ប្រការ ៤ : រាល់ការប្រព្រឹត្តល្មើស និងបទបញ្ញត្តិនៃប្រកាសនេះត្រូវពិន័យ ឬត្រូវផ្តន្ទាទោសតាមច្បាប់ដូចមានចែងនៅក្នុងជំពូកទី ១៦ នៃច្បាប់ការងារ ។

ប្រការ ៥ : ប្រកាសរបស់ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជនលេខ ១៦ សកអ.អក.៩៣ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៩៣ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៦ : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ស៊ុយ សែម

* * * * *

ឧបសម្ព័ន្ធ
នៃប្រកាសលេខ : ៩២ សកអ
ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ១៩៩៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
****

សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន

............ថ្ងៃទី ....ខែ......... ឆ្នាំ ....

ទំហំ ២០ សម × ៣០ សម

- ឈ្មោះគ្រឹះស្ថាន : ....
....
- ផ្នែកនៃសកម្មភាពសេដ្ឋកិច្ច :..
....
- អាសយដ្ឋាន : ....
....
- នាម និង គោត្តនាមនិយោជក..
....
- កាលបរិច្ឆេទនៃការចេញសៀវភៅបញ្ជី : ....
....

បោះត្រាហត្ថលេខា
របស់អធិការការងារ ......

លេខទំព័រ :........

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ១៩៩៧

ប្រកាសលេខ : ៩៣ សករអ

ស្តីពីការបង្កើតសៀវភៅបើកប្រាក់

* * * * *

រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារនិងអតីតយុទ្ធជន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការងារដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស.រកម ០៣៩៧_០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៧
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

សម្រេច

ប្រការ ១ : នាយក ឬ ម្ចាស់សហគ្រាស ឬ គ្រឹះស្ថាន ឧស្សាហកម្ម រ៉ែ ពាណិជ្ជកម្ម សិប្បកម្ម កសិកម្ម សេវា ដឹកជញ្ជូនតាមផ្លូវគោក ឬតាមផ្លូវទឹក ជាប្រយោជន៍សាធារណៈ ឬ ពាក់កណ្តាលសាធារណៈ ឬ ឯកជន ក្រៅសាសនា ឬក្នុងសាសនា ទោះមានលក្ខណៈជាការបង្រៀនវិជ្ជាជីវៈ ឬការកុសលក៏ដោយព្រមទាំងវិជ្ជាជីវៈសេរីនៃសមាគម ឬ នៃក្រុមប្រភេទណាក៏ដោយត្រូវកាន់ដោយទៀងទាត់ជាដរាបនូវសៀវភៅបើកប្រាក់មួយដែលមានគំរូដូចក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ។

ប្រការ ២ : សៀវភៅបើកប្រាក់នេះ និង ទុកជាត្រឹមត្រូវបាន លុះត្រាតែមានចុះលេខគ្រប់ទំព័រ និង ចុះហត្ថលេខាសង្ខេបដោយអធិការការងារ ។ កាលណាសហគ្រាសណាចង់ធ្វើ

សៀវភៅបើកប្រាក់តាមរបៀបផ្សេងពីគំរូដូចមានចែងក្នុងប្រការ១ ប៉ុន្តែមានចុះពតិមាន និងបែបបទត្រួតពិនិត្យដូចគ្នានោះ សហគ្រាសនោះអាចធ្វើពាក្យសុំទៅនាយកដ្ឋានអធិការកិច្ចការងារ (ចំពោះរាជធានីភ្នំពេញ) និងនៅអធិការដ្ឋានសង្គមកិច្ចការងារ និងអតីតយុទ្ធជនខេត្ត ក្រុងបាន (ចំពោះខេត្ត ក្រុងផ្សេងទៀត) ។

ប្រការ ៣ : សៀវភៅបើកប្រាក់នេះត្រូវទុកនៅក្នុងការិយាល័យបេឡា ឬទីចាត់ការនៃសហគ្រាស ដើម្បីងាយស្រួលដល់ការត្រួតពិនិត្យ ។ កាលណាប្រើសៀវភៅនេះគ្រប់ទំព័រហើយ និយោជកត្រូវមានកាតព្វកិច្ចរក្សាទុកអោយគង់វង្សក្នុងរយៈពេល ៣ ឆ្នាំ ។ អធិការការងារ ឬ អភិបាលការងារអាចទាររកសៀវភៅនេះនៅគ្រប់ពេលវេលា ។

ប្រការ ៤ : រាល់ការប្រព្រឹត្តល្មើសនឹងបទបញ្ញត្តិនៃប្រកាសនេះត្រូវពិន័យ ឬត្រូវផ្តន្ទាទោសតាមច្បាប់ដូចមានចែងក្នុងជំពូកទី ១៦ នៃច្បាប់ការងារ ។

ប្រការ ៥ : ប្រកាសរបស់ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន លេខ ៨៣០ សកអ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៦ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៦ : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ស៊ុយ សែម

* * * * *

ឧបសម្ព័ន្ធ
នៃប្រកាសលេខ ៩៣ សកអ.
ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ១៩៩៧

សៀវភៅបើកប្រាក់
LE LIVRE DE PAYE

គ្រឹះស្ថាន..............
ETABLISSEMENT

ផ្នែកនៃសកម្មភាពសេដ្ឋកិច្ច..................
BRANCHE D'ACTIVITE ECONOMIQUE

អាសយដ្ឋាន.................
ADRESSE

(ទំហំ ២៩ ស.ម គុណ ៣៥ ស.ម)

សៀវភៅបើកប្រាក់

LE LIVRE DE PAYE

គ្រឹះស្ថាន...

ETABLISSEMENT...

ផ្នែកសកម្មភាពសេដ្ឋកិច្ច...

BRANCHE D'ACTIVITE ECONOMIQUE ....

អាសយដ្ឋាន...

ADRESSE...

៧—ទីស្តីការក្រសួងធម្មការ និងសាសនា

សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ៥២_៩៧ កធស

* * * * *

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រម លេខ នស.រកម.០១៩៦_១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា លេខ ០៦ នស.១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ។
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា ។
- បានឃើញពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទនិកាយ សេវេនដេយអាត់វេនទីស្ទ របស់លោក វណ្ណ សារ៉ាន់ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៩៦ ។
- បានឃើញចំណារបញ្ជូនរបស់ឯកឧត្តមអភិបាលខេត្តកណ្តាលលេខ ០៣៣ សណ ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ។

សំរេច

ប្រការ ១ : អនុញ្ញាតជាគោលការណ៍អោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទ និកាយសេវេនដេយអាត់វេនទីស្ទ នៃព្រះវិហារឈ្មោះហៅថា «សេវេនដេយ អាត់វេនទីស្ទ» មួយកន្លែងដែលមានទីតាំង ស្ថិតនៅផ្ទះលេខ ៣០៣ ផ្លូវលេខ ០១ ឃុំតគី ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

ប្រការ ២ : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទនៃព្រះវិហារឈ្មោះ «សេវ៉េនដេយ អាត់វ៉េនទីស្ទ» ត្រូវអនុញ្ញាតអោយប្រើប្រាស់ និង ផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗ របស់លទ្ធិសាសនាគ្រិស្ទដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : បរិស័ទទាំងអស់នៃព្រះវិហារឈ្មោះ « សេវ៉េនដេយ អាត់វ៉េនទីស្ទ » ត្រូវគោរព និង អនុវត្តន៍អោយបានត្រឹមត្រូវ ម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និង រាល់បទបញ្ញត្តិផ្សេងៗរបស់ក្រសួងធម្មការនិងសាសនា ។ អ្នកដឹកនាំនៃសាខាស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាពនិង ទំនាក់ទំនងអោយបានល្អ ជាមួយស្ថាប័នពាក់ព័ន្ធសន្សាជាដាច់ខាត មិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និង សណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ទាំងឡាយណាដែលផ្ទុយអំពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា_មន្ទីរធម្មការ និង សាសនា ខេត្តកណ្តាល និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការណ៍អនុវត្តន៍ សេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហឿន វណ្ណារ័ត្ន

* * * * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ៥៣_៩៧ កធស

* * * * *

·រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រម លេខ នស.រកម ០១៩៦_១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា លេខ ០៦ នស ១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ។
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា ។
- បានឃើញពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តនិកាយ សេវេនដេយ អាត់វេនទីស្ទ របស់លោក ជុំ សមិទ្ធិ ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ ១៩៩៧ ។
- បានឃើញចំណារបញ្ជូនរបស់ឯកឧត្តមអភិបាលខេត្តសៀមរាបលេខ ០៣០៩ខសរ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ។

សំរេច

ប្រការ ១ : អនុញ្ញាតជាគោលការណ៍អោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តនិកាយប្រូតេស្តង់ក្រុមសេវេនដាយ អាត់វេនទីស្ទ នៃព្រះវិហារឈ្មោះហៅថា «សេវេនដេយ អាត់វេនទីស្ទ សំរោង» មួយកន្លែងដែលមានទីតាំងស្ថិតនៅផ្លូវលេខ ៦៨ ឃុំ សំរោង ស្រុក សំរោង ខេត្តសៀមរាប ។

ប្រការ ២ : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តនៃព្រះវិហារឈ្មោះ «សេវេនដេយ អាត់វេនទីស្ទ សំរោង» ត្រូវអនុញ្ញាតអោយប្រើប្រាស់ និង ផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗ របស់លទ្ធិសាសនាគ្រិស្តដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : បរិស័ទទាំងអស់នៃព្រះវិហារឈ្មោះ«សេវេនដេយ អាត់វេនទីស្ទសំរោង» ត្រូវគោរព និង អនុវត្តន៍អោយបានត្រឹមត្រូវ ម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និង រាល់បទបញ្ញត្តិផ្សេងៗរបស់ក្រសួងធម្មការនិងសាសនា ។ អ្នកដឹកនាំនៃសាខាស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាព និង ទំនាក់ទំនងអោយបានល្អ ជាមួយស្ថាប័នពាក់ព័ន្ធ សន្យាជាដាច់ខាត មិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និង សណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ទាំងឡាយណាដែលផ្ទុយអំពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា_មន្ទីរធម្មការ និង សាសនា ខេត្តសៀមរាប និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការណ៍អនុវត្តន៍ សេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហឿន វណ្ណារ័ត្ន

*****

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ៥៤_៩៧ កធស

*****

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រម លេខ នស.រកម ០១៩៦_១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា លេខ ០៦ នស ១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ។
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា ។
- បានឃើញពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះ នៃសាសនាព្រះនាងគង់ស៊ីអ៊ីម (ចិន) របស់លោកស្រី នាង សារឿន ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ។

– បានឃើញលិខិតបញ្ជាក់ ការយល់ព្រមអំពីទីតាំង របស់ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ប្រចាំរាជធានីភ្នំពេញលេខ ១៨៧ លសស ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៩៧ ។

សំរេច

ប្រការ ១ : អនុញ្ញាតជាគោលការណ៍អោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះ នៃសាសនាព្រះនាងគង់ស៊ីអ៊ឹម (ចិន) ដែលព្រះវិហារមានឈ្មោះហៅថា «សីញអ៊ី ខុងមីង ស៊ិនតៅ»មួយកន្លែងមានទីតាំងស្នាក់ការកណ្តាលស្ថិតនៅផ្ទះលេខ ៧D ផ្លូវលេខ ២៣០ សង្កាត់ផ្សារដើមគរ ខ័ណ្ឌទួលគោករាជធានីភ្នំពេញ ។

ប្រការ ២: ស្នាក់ការថ្វាយបង្គំព្រះ នៃសាសនាព្រះនាងគង់ស៊ីអ៊ឹម (ចិន) ព្រះវិហារឈ្មោះ«សីញអ៊ីខុងមីងស៊ីនតៅ» ត្រូវអនុញ្ញាតអោយប្រើប្រាស់ និង ផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗរបស់លទ្ធិសាសនាព្រះនាងគង់ស៊ីអ៊ឹម ដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : បរិស័ទទាំងអស់របស់ព្រះវិហារឈ្មោះ «សីញអ៊ី ខុងមីង ស៊ិនតៅ» ត្រូវគោរព និងអនុវត្តន៍អោយបានត្រឹមត្រូវ ម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និង រាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការនិងសាសនា ។ អ្នកដឹកនាំនៃសាខាស្នាក់ការខាងលើនេះ ចាំបាច់ត្រូវមានអ្នកទទួលខុសត្រូវ ចេះនិយាយ–សរសេរអក្សរខ្មែរហើយត្រូវមានសាមគ្គីភាព និង ទំនាក់ទំនងអោយបានល្អ ជាមួយស្ថាប័នពាក់ព័ន្ធ សន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និង សណ្តាប់ធ្នាប់របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ទាំងឡាយណាដែលផ្ទុយអំពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា–មន្ទីរធម្មការ និង សាសនា ខេត្តសៀមរាប និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការណ៍អនុវត្តន៍ សេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហឿន ចន្ទរ័ត្ន

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ៥៥_៩៧ កធស

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រម លេខ នស.រកម ០១៩៦_១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា លេខ ០៦ នស ១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ។
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា ។
- បានឃើញពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទ និកាយ សេវេនដេយ អាត់វេនទីស្ទ របស់លោក ឈួ ធឿន ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៦ ។
- បានឃើញចំណារបញ្ជូនរបស់ឯកឧត្តម អភិបាល ខេត្តសៀមរាប លេខ ២១៥៦ ខសរ ចុះថ្ងៃ ទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ ។

សំរេច

ប្រការ ១ : អនុញ្ញាតជាគោលការណ៍អោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទ និកាយសេវេន-ដេយអាត់វេនទីស្ទ នៃព្រះវិហារឈ្មោះហៅថា «សេវេនដេយ អាត់វេនទីស្ទស្រែប្រាំង» មួយ កន្លែងដែលមានទីតាំងស្ថិតនៅឃុំជើងធៀន ស្រុកចុងកាល់ ខេត្តសៀមរាប ។

ប្រការ ២ : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទនៃព្រះវិហារឈ្មោះ «សេវេនដេយ អាត់វេនទីស្ទស្រែប្រាំង»ត្រូវអនុញ្ញាតអោយប្រើប្រាស់ និង ផ្សព្វផ្សាយនូវរាល់ឯកសារផ្សេង ៗ របស់លទ្ធិសាសនាគ្រិស្ទដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : បរិស័ទទាំងអស់នៃព្រះវិហារឈ្មោះ «សេវេនដេយ អាត់វេនទីស្ទស្រែប្រាំង»ត្រូវគោរព និង អនុវត្តន៍អោយបានត្រឹមត្រូវ ម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និង

រាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការនិងសាសនា ។ អ្នកដឹកនាំនៃសាខាស្នាក់ការខាងលើនេះត្រូវមានសាមត្ថិភាព និង ទំនាក់ទំនងអោយបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និង សណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ទាំងឡាយណាដែលផ្ទុយអំពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា_មន្ទីរធម្មការ និង សាសនា ខេត្តសៀមរាប និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការណ៍អនុវត្តន៍ សេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហៀង វណ្ណារ័ត្ន

* * * * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ៥៦_៩៧ កធស

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រម លេខ នស.រកម ០១៩៦_១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦

- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា លេខ ០៦ នស ១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ។
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា ។
- បានឃើញពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទ និកាយ សេវេនដេយ អាត់វេនទីស្ទ របស់លោកស្រី ម៉ៃ រ៉ាដៀង ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៩៦ ។
- បានឃើញចំណារបញ្ជូនរបស់ឯកឧត្តម អភិបាល ខេត្តសៀមរាប លេខ ២១៥៣ ខសរ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ ។

សំរេច

ប្រការ ១ : អនុញ្ញាតជាគោលការណ៍អោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទ និកាយសេវេន-ដេយវេនទីស្ទ នៃព្រះវិហារឈ្មោះហៅថា «សេវេនដេយ អាត់វេនទីស្ទភូមិជ័យ» មួយកន្លែងដែលមានទីតាំងស្ថិតនៅភូមិជ័យ ឃុំស្រណាល ស្រុកក្រឡាញ់ ខេត្តសៀមរាប។

ប្រការ ២ : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទនៃព្រះវិហារឈ្មោះ «សេវេនដេយ អាត់វេនទីស្ទភូមិជ័យ» ត្រូវអនុញ្ញាតអោយប្រើប្រាស់ និង ផ្សព្វផ្សាយនូវរាល់ឯកសារផ្សេង ៗ របស់លទ្ធិសាសនាគ្រិស្ទដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : បរិស័ទទាំងអស់នៃព្រះវិហារឈ្មោះ «សេវេនដេយ អាត់វេនទីស្ទភូមិជ័យ» ត្រូវគោរព និង អនុវត្តន៍អោយបានត្រឹមត្រូវ ម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និង រាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការនិងសាសនា ។ អ្នកដឹកនាំនៃសាខាស្នាក់ការខាងលើនេះត្រូវមានសាមគ្គីភាព និង ទំនាក់ទំនងអោយបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាពខាងជំនឿសាសនា និង សណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ទាំងឡាយណាដែលផ្ទុយអំពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា–មន្ទីរធម្មការ និង សាសនា ខេត្តសៀមរាប និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការណ៍អនុវត្តន៍ សេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខេង្សៀន វណ្ណរ័ត្ន

* * * * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ៥៧_៩៧ កធស

* * * * *

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រម លេខ នស.រកម ០១៩៦_១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា លេខ ០៦ នស ១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ។
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា ។
- បានឃើញពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទនិកាយប្រូតេស្តង់ ក្រុមសម្ព័ន្ធគ្រិស្ទានដំណឹងល្អខ្មែរ របស់លោក ហេង សាអែម ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៦
- បានឃើញចំណារបញ្ជូនរបស់ឯកឧត្តម អភិបាល ខេត្តកណ្តាល លេខ ០៣០ ស.ណ ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៩៧

សំរេច

ប្រការ ១ : អនុញ្ញាតជាគោលការណ៍អោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទ និកាយប្រូតេស្តង់ ក្រុមសម្ព័ន្ធគ្រិស្ទានដំណឹងល្អខ្មែរនៃព្រះវិហារឈ្មោះហៅថា «ពន្លកថ្មី តារាប» មួយកន្លែងដែលមានទីតាំងស្ថិតនៅផ្លូវលំ ឃុំតគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

ប្រការ ២ : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទនៃព្រះវិហារឈ្មោះ «ពន្លកថ្មីតារាប» ត្រូវអនុញ្ញាតអោយប្រើប្រាស់ និង ផ្សព្វផ្សាយនូវភាសាឯកសារផ្សេងៗ របស់លទ្ធិសាសនាគ្រិស្ទដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : បរិស័ទទាំងអស់នៃព្រះវិហារឈ្មោះ «ពន្លកថ្មីតារាប»ត្រូវគោរព និង អនុវត្តន៍អោយបានត្រឹមត្រូវ ម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និង រាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការនិងសាសនា ។ អ្នកដឹកនាំនៃសាខាស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាព និង ទំនាក់ទំនងអោយបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាព ខាងជំនឿសាសនា និង សណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ទាំងឡាយណាដែលផ្ទុយអំពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា_មន្ទីរធម្មការ និង សាសនា ខេត្តកណ្តាល និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការណ៍អនុវត្តន៍ សេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហៀង វណ្ណារិទ្ធ

* * * * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ៥៨_៩៧ កធស

* * * * *

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រម លេខ នស.រកម ០១៩៦_១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា លេខ ០៦ នស ១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ។
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា ។
- បានឃើញពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទ និកាយ សេវេនដេយ អាត់វេនទីស្ទ របស់លោក សេន សម្បត្តិ ចុះថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ១៩៩៤
- បានឃើញចំណារបញ្ជូនរបស់ឯកឧត្តម អភិបាល ខេត្តកំពង់ស្ពឺ លេខ ៦២០ សរសណ ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៩៤

សំរេច

ប្រការ ១ : អនុញ្ញាតជាគោលការណ៍អោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទ និកាយសេវេនដេយ អាត់វេនទីស្ទ នៃព្រះវិហារឈ្មោះហៅថា «សេវេនដេយ អាត់វេនទីស្ទ ភូមិច្បារមន» មួយកន្លែងដែលមានទីតាំងស្ថិតនៅផ្លូវច្បារមន ភូមិការដ្ឋង សង្កាត់ច្បារមន ស្រុកទីរួមខេត្តកំពង់ស្ពឺ ខេត្តកំពង់ស្ពឺ ។

ប្រការ ២ : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទនៃព្រះវិហារឈ្មោះ «សេវេនដេយ អាត់វេនទីស្ទ ច្បារមន» ត្រូវអនុញ្ញាតអោយប្រើប្រាស់ និង ផ្សព្វផ្សាយនូវរាល់ឯកសារផ្សេង ។ របស់លទ្ធិសាសនាគ្រិស្ទដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : បរិស័ទទាំងអស់នៃព្រះវិហារឈ្មោះ «សេវេនដេយ អាត់វេនទីស្ទ ច្បារមន» ត្រូវគោរព និង អនុវត្តន៍អោយបានត្រឹមត្រូវ ម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និង រាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការនិងសាសនា ។ អ្នកដឹកនាំនៃសាខាស្នាក់ការខាងលើនេះត្រូវមានសាមគ្គីភាព និង ទំនាក់ទំនងអោយបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាព ខាងជំនឿសាសនា និង សណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ទាំងឡាយណាដែលផ្ទុយអំពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា មន្ទីរធម្មការ និង សាសនា ខេត្តកំពង់ស្ពឺ និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការណ៍អនុវត្តន៍ សេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហៀន វណ្ណីរ៉ុ

* * * * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ៥៩_៩៧ គធស

* * * * *

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

- បានឃើញច្បាប់ស្ដីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រម លេខ នស.រកម ០១៩៦_១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្ដីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា លេខ ០៦ នស ១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ។
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្ដីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា ។
- បានឃើញពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទ និកាយ សេវេនដេយ អាត់វេនទីស្ទរបស់លោក សេង សំអ៊ិន ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ១៩៩៦
- បានឃើញចំណារបញ្ជូនរបស់ឯកឧត្ដម អភិបាលខេត្តសៀមរាប លេខ ២១៥៤ ខសរ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ : អនុញ្ញាតជាគោលការណ៍អោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទ និកាយសេវេនដេយ អាត់វេនទីស្ទ នៃព្រះវិហារឈ្មោះហៅថា «សេវេនដេយ អាត់វេនទីស្ទ ក្រុងសៀមរាប» មួយកន្លែងដែលមានទីតាំងស្ថិតនៅផ្ទះលេខ ០៥៨ ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ។

ប្រការ ២ : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទនៃព្រះវិហារឈ្មោះ «សេវេនដេយ អាត់វេនទីស្ទ ក្រុងសៀមរាប» ត្រូវអនុញ្ញាតអោយប្រើប្រាស់ និង ផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗ របស់លទ្ធិសាសនាគ្រិស្ទដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : បរិស័ទទាំងអស់នៃព្រះវិហារឈ្មោះ «សេវេនដេយ អាត់វេនទីស្ទក្រុងសៀមរាប» ត្រូវគោរព និង អនុវត្តន៍អោយបានត្រឹមត្រូវ មឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និង រាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការនិងសាសនា ។ អ្នកដឹកនាំនៃសាខាស្នាក់ការខាងលើនេះត្រូវមានសាមគ្គីភាព និង ទំនាក់ទំនងអោយបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាព ខាងជំនឿសាសនា និង សណ្ដាប់ធ្នាប់ របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ទាំងឡាយណាដែលផ្ទុយអំពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា_មន្ទីរធម្មការ និង សាសនា ខេត្តសៀមរាបនិង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការណ៍អនុវត្តន៍ សេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហៀង វណ្ណារិទ្ធ

* * * * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ៦០_៩៧ កធស

* * * * *

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រម លេខ នស.រកម ០១៩៦_១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា លេខ ០៦ នស ១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ។
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា ។
- បានឃើញពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទ និកាយ សេវ៉េនដេយ អាត់វេនទីស្ទរបស់លោក ស៊ិន វណ្ណឌី ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៩៦

– បានឃើញចំណារបញ្ជូនរបស់ឯកឧត្តម អភិបាល ខេត្តសៀមរាប លេខ ២១៥៥ ខសរ ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦

សំរេច

ប្រការ ១ : អនុញ្ញាតជាគោលការណ៍អោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ត និកាយសេវេនដេយ អាត់វេនទីស្ទ នៃព្រះវិហារឈ្មោះហៅថា «សេវេនដេយ អាត់វេនទីស្ទ ភូមិវាល» មួយកន្លែងដែលមានទីតាំងស្ថិតនៅភូមិវាល ឃុំគោកចក ស្រុកសៀមរាប ខេត្តសៀមរាប ។

ប្រការ ២ : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្តនៃព្រះវិហារឈ្មោះ «សេវេនដេយ អាត់វេនទីស្ទ ភូមិវាល» ត្រូវអនុញ្ញាតអោយប្រើប្រាស់ និង ផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗ របស់លទ្ធិសាសនាគ្រិស្តដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : បរិស័ទទាំងអស់នៃព្រះវិហារឈ្មោះ «សេវេនដេយ អាត់វេនទីស្ទ ភូមិវាល»ត្រូវគោរព និង អនុវត្តន៍អោយបានត្រឹមត្រូវ ម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និង រាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការនិងសាសនា ។ អ្នកដឹកនាំនៃសាខាស្នាក់ការខាងលើនេះត្រូវមានសាមគ្គីភាព និង ទំនាក់ទំនងអោយបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាព ខាងជំនឿសាសនា និង សណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ទាំងឡាយណាដែលផ្ទុយអំពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា_មន្ទីរធម្មការ និង សាសនា ខេត្តសៀមរាបនិង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការណ៍អនុវត្តន៍ សេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហៀង ចណ្ណារ័ត្ន

* * * * *

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ៦១_៩៧ កធស

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រម លេខ នស.រកម ០១៩៦_១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា លេខ ០៦ នស ១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤។
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា ។
- បានឃើញពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទ និកាយ ប្រូតេស្តង់ ក្រុមជំនុំបេសកកម្មសេចក្តីមេត្តាករុណានៃព្រះគ្រិស្ទ របស់លោក មៀច ស៊ឿ ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦
- បានឃើញចំណារបញ្ជូនរបស់ឯកឧត្តមអភិបាលខេត្តកំពង់ស្ពឺ លេខ ០០២៧សរសណ ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ១៩៩៧

សំរេច

ប្រការ ១ : អនុញ្ញាតជាគោលការណ៍អោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទ និកាយប្រូតេស្តង់ក្រុមជំនុំបេសកកម្ម សេចក្តីមេត្តាករុណានៃព្រះគ្រិស្ទ នៃព្រះវិហារឈ្មោះហៅថា «ក្រុមជំនុំបេសកកម្មសេចក្តីមេត្តាករុណា នៃព្រះគ្រិស្ទ» មួយកន្លែងដែលមានទីតាំងស្ថិតនៅ ឃុំកណ្តោលដុំ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ ។

ប្រការ ២ : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទនៃព្រះវិហារឈ្មោះ «ក្រុមជំនុំបេសកកម្មសេចក្តីមេត្តាករុណានៃព្រះគ្រិស្ទ» ត្រូវអនុញ្ញាតអោយប្រើប្រាស់ និង ផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗ របស់លទ្ធិសាសនាគ្រិស្ទដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : បរិស័ទទាំងអស់នៃព្រះវិហារឈ្មោះ «ក្រុមជំនុំបេសកកម្មសេចក្តីមេត្តាករុណានៃព្រះគ្រិស្ទ» ត្រូវគោរពនិងអនុវត្តន៍អោយបានត្រឹមត្រូវ ម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និង រាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការនិងសាសនា ។ អ្នកដឹកនាំនៃសាខាស្នាក់ការខាងលើនេះ ត្រូវមានសាមគ្គីភាព និង ទំនាក់ទំនងអោយបានល្អជាមួយស្ថាប័នពាក់ព័ន្ធ សន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាព ខាងជំនឿសាសនា និង សណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ទាំងឡាយណាដែលផ្ទុយអំពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា_មន្ទីរធម្មការ និង សាសនា ខេត្តកំពង់ស្ពឺនិង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការណ៏អនុវត្តន៍ សេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហៀង វណ្ណារិត្ន

* * * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ១៩៩៧

សេចក្តីសំរេចលេខ ៦២_៩៧ កធស

* * * *

រដ្ឋលេខាធិការក្រសួងធម្មការ និង សាសនា

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ដែលប្រកាសអោយប្រើតាមព្រះរាជក្រម លេខ នស.រកម ០១៩៦_១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា លេខ ០៦ នស ១៩៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ។
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងធម្មការ និង សាសនា ។
- បានឃើញពាក្យសុំបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទ និកាយ ប្រូតេស្តង់ ក្រុមជំនុំ បេសកកម្មសេចក្តីមេត្តាករុណានៃព្រះគ្រិស្ទ របស់លោក **ចាន់ សុគន្ធា** ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៩៦
- បានឃើញចំណារបញ្ជូនរបស់ឯកឧត្តម អភិបាលខេត្តសៀមរាបលេខ ២៤០៤ ខសរ ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៦ ។

សំរេច

ប្រការ ១ : អនុញ្ញាតជាគោលការណ៍អោយបើកសាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទ និកាយប្រូតេស្តង់ ក្រុមជំនុំបេសកកម្ម សេចក្តីមេត្តាករុណានៃព្រះគ្រិស្ទ នៃព្រះវិហារឈ្មោះហៅថា «ក្រុមជំនុំបេសកកម្មសេចក្តីមេត្តាករុណា នៃព្រះគ្រិស្ទ» មួយកន្លែងដែលមានទីតាំងស្ថិតនៅផ្ទះលេខ ០២៣៣ ផ្លូវលេខ ៦ ឃុំស្វាយក្រាម ស្រុកសៀមរាប ខេត្តសៀមរាប ។

ប្រការ ២ : សាខាស្នាក់ការថ្វាយបង្គំព្រះគ្រិស្ទនៃព្រះវិហារឈ្មោះ «ក្រុមជំនុំបេសកកម្មសេចក្តីមេត្តាករុណានៃព្រះគ្រិស្ទ» ត្រូវអនុញ្ញាតអោយប្រើប្រាស់ និង ផ្សព្វផ្សាយនូវរាល់ឯកសារផ្សេងៗ របស់លទ្ធិសាសនាគ្រិស្ទដែលមានលក្ខណៈជាសាសនាសុទ្ធសាធ ។

ប្រការ ៣ : បរិស័ទទាំងអស់នៃព្រះវិហារឈ្មោះ «ក្រុមជំនុំបេសកកម្មសេចក្តីមេត្តាករុណានៃព្រះគ្រិស្ទ»ត្រូវគោរពនិងអនុវត្តន៍អោយបានត្រឹមត្រូវ ម៉ឺងម៉ាត់តាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និង រាល់បទបញ្ញត្តិផ្សេងៗ របស់ក្រសួងធម្មការនិងសាសនា ។ អ្នកដឹកនាំនៃសាខាស្នាក់ការខាងលើនេះត្រូវមានសាមគ្គីភាព និង ទំនាក់ទំនងអោយបានល្អជា

ឬយស្ថាប័នពាក់ព័ន្ធ សន្យាជាដាច់ខាតមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិសេរីភាព ខាងជំនឿសាសនា និង សណ្តាប់ធ្នាប់ របៀបរៀបរយសង្គម ។

ប្រការ ៤ : រាល់ការអនុវត្តន៍ទាំងឡាយណាដែលផ្ទុយពីសេចក្តីសំរេចខាងលើនេះ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : នាយកដ្ឋានសាសនា–មន្ទីរធម្មការ និង សាសនា ខេត្តសៀមរាបនិង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដែលមានភារកិច្ចពាក់ព័ន្ធ ត្រូវសហការណ៍អនុវត្តន៍ សេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

ប្រការ ៦ : សេចក្តីសំរេចនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ហឿន វណ្ណារ័ត្ន

* * * * *

បោះពុម្ពនៅរោងពុម្ព ទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ៨០០ ច្បាប់

តម្លៃ ២៣៥០ រៀល